# ព្រះរាជក្រម នស/រកម/០៧៩៩/០២

## យើង

## ព្រះបាទសម្ដេច ព្រះនរោត្ដម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្ដម

## ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

***

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ១៩៩៣
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើជាផ្លូវការ នូវច្បាប់ធម្មនុញ្ញ ស្ដីពីវិសោធនកម្មមាត្រា១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី៨ ដល់ជំពូកទី១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការចាត់តាំងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម ជស/រកម០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពីការងារ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើ ច្បាប់ស្ដីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
- តាមសេចក្ដីក្រាបបង្គំទូលស្នើសុំអំពីសម្ដេចនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រី ក្រសួងសង្គមកិច្ច ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

## ប្រកាសឲ្យប្រើ

ច្បាប់ស្ដីពី ការអនុម័តយល់ព្រមលើអនុសញ្ញាលេខ ៨៧-៩៨-១០០-១០៥-១១១ និង១៣៨ ដែលរដ្ឋសភាបានអនុម័ត នៅថ្ងៃទី០៣ ខែមិថុនា ឆ្នាំ១៩៩៩ នាសម័យប្រជុំរដ្ឋសភាលើកទី២ នីតិកាលទី២

និងដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមលើទំរង់ និងគតិនៃច្បាប់នេះទាំងស្រុងនៅថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ១៩៩៩ នាសម័យប្រជុំពេញអង្គលើកទី១ នីតិកាលទី១ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅ :

# ច្បាប់
## ស្តីពី
## ការអនុម័តយល់ព្រមលើអនុសញ្ញាលេខ ៨៧ ៩៨ ១០០ ១០៥ ១១១ និង ១៣៨ នៃអង្គការអន្តរជាតិខាងការងារ

មាត្រា ១._ អនុម័តយល់ព្រមលើអនុសញ្ញា នៃអង្គការអន្តរជាតិខាងការងារ :

- លេខ៨៧ ស្តីពីសេរីភាព នៃសមាគម និងការការពារសិទ្ធិ នៃការបង្កើតសមាគម ដែលត្រូវបានអនុម័តដោយមហាសន្និបាតនៃអង្គការអន្តរជាតិ ខាងការងារនៅហ្សឺណែវ នាថ្ងៃទី០៩ ខែកក្កដា ឆ្នាំ១៩៤៨ ។
- លេខ ៩៨ ស្តីពីការអនុវត្តន៍គោលការណ៍ ស្តីអំពីសិទ្ធិនៃការបង្កើតសមាគម និងសិទ្ធិនៃការចរចាជាសមូហភាព ដែលត្រូវបានអនុម័តដោយមហាសន្និបាត នៃអង្គការអន្តរជាតិខាងការងារនៅហ្សឺណែវ នាថ្ងៃទី០១ ខែកក្កដា ឆ្នាំ១៩៤៩ ។
- លេខ ១០០ ស្តីពីប្រាក់ឈ្នួលស្មើគ្នា សំរាប់កម្មករ និយោជិត បុរស ស្ត្រីចំពោះការងារមានតំលៃស្មើគ្នា ដែលត្រូវបានអនុម័ត ដោយមហាសន្និបាត នៃអង្គការអន្តរជាតិខាងការងារ នៅហ្សឺណែវនាថ្ងៃទី២៩ ខែមិថុនា ឆ្នាំ១៩៥១ ។
- លេខ ១០៥ ស្តីពីការលុបបំបាត់ការងារដោយបង្ខំ ដែលត្រូវបានអនុម័តដោយមហាសន្និបាតនៃអង្គការអន្តរជាតិខាងការងារ នៅហ្សឺណែវ នាថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៥៧ ។
- លេខ ១១១ ស្តីពីការរើសអើង ក្នុងការងារ និងមុខរបរដែលត្រូវបានអនុម័ត ដោយមហាសន្និបាតនៃអង្គការអន្តរជាតិខាងការងារ នៅហ្សឺណែវ នាថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៥៨ ។
- លេខ ១៣៨ ស្តីពីអាយុអប្បបរមាអាចចូលធ្វើការបាន ដែលត្រូវបានអនុម័តដោយមហាសន្និបាតនៃអង្គការអន្តរជាតិខាងការងារ នៅហ្សឺណែវ នាថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៧៣ ។

ហើយដែលមានអត្ថបទទាំងស្រុងជូនភ្ជាប់មកជាមួយនេះ ។

មាត្រា ២.- រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវបន្តរាល់នីតិវិធី ដើម្បីអនុវត្តអនុសញ្ញាទាំងនេះ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ១៩៩៩

បានបង្គំទូលថ្វាយ — ក្នុងព្រះបរមនាម និងតាមព្រះរាជបង្គាប់

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ — ប្រមុខរដ្ឋ ស្តីទី

នាយករដ្ឋមន្ត្រី — ហត្ថលេខា

ហត្ថលេខា — ជា ស៊ីម

ហ៊ុន សែន

បានជំរាបជូនសម្ដេចនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ

និងយុវនីតិសម្បទា

ហត្ថលេខា

អ៊ិត សំហេង

***

ព្រះរាជក្រម នស/រកម/០៧៩៩/០៣

យើង

ព្រះបាទសម្ដេច ព្រះនរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

***

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ១៩៩៣
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើជាផ្លូវការ នូវច្បាប់ធម្មនុញ្ញ ស្ដីពីវិសោធនកម្មមាត្រា១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី៨ ដល់ជំពូកទី១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការចាត់តាំងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា